ការយល់ដឹងអំពី
ជំងឺស្វាយ

តើ ជំងឺស្វាយគឺជាអ្វី?

រោគស្វាយគឺបណ្តាលមកពីបាក់តេរីហៅថា "Treponema pallidum"។ រោគស្វាយត្រូវបានស្ទើរតែលុបបំបាត់ក្នុងឆ្នាំ 2000 ប៉ុន្តែចាប់តាំងពីពេលនេះមកទីក្រុងឡុងប៊ិចបានរកឃើញមានការកើនឡើងជាលំដាប់មកវិញ។ យោងតាមប្រវត្តិសាស្ត្រ អត្រាបុរសដែលរួមភេទជាមួយបុរសគឺខ្ពស់ជាងគេ ទោះជាយ៉ាងណាក៏ដោយ ក៏យើងឃើញអត្រាកើនឡើងចំពោះស្ត្រីផងដែរ។ រោគស្វាយអាចព្យាបាលបានដោយការប្រើថ្នាំអង់ទីប៊ីយោទិច។ ប្រសិនបើមិនទទួលបានការព្យាបាលទេ រោគស្វាយអាចបណ្តាលឱ្យខូចខាតជាអចិន្ត្រៃយ៍ដល់បេះដូង ខួរក្បាល និងសរីរាង្គដទៃទៀត។ ការមានរោគស្វាយអាចបង្កើនឱកាសរបស់អ្នកក្នុងការចម្លង ឬទទួលបានមេរោគអេដស៍។

តើ អ្នកណាខ្លះឆ្លងរោគស្វាយ?

រោគស្វាយអាចឆ្លងតាមរយៈ ទ្វារមាស ទ្វារលាមក ការរួមភេទតាមមាត់ ឬការប៉ះពាល់ស្បែកទៅអ្នកដែលមានមេរោគស្វាយ។ អ្នកមានផ្ទៃពោះដែលមានរោគស្វាយ ក៏អាចឆ្លងទៅកូននៅក្នុងផ្ទៃកំឡុងពេលមានផ្ទៃពោះផងដែរ។

តើ រោគស្វាយមានរោគសញ្ញាអ្វីខ្លះ?

រោគស្វាយគឺជាជំងឺមួយក្នុងច្រើនដំណាក់កាល។ ដំណាក់កាលនីមួយៗត្រូវបានកំណត់ដោយរោគសញ្ញាផ្សេងៗគ្នា។ រោគសញ្ញាទាំងនេះកើតមានជាហូរហែ ប៉ុន្តែសុះត្រាតែរោគស្វាយត្រូវបានព្យាបាល និងជាសះស្បើយ វានឹងនៅតែមាននៅក្នុងខ្លួន ហើយអាចបណ្តាលឱ្យខូចខាតយ៉ាងធ្ងន់ធ្ងរទៅតាមពេលវេលា។ ដំណាក់កាលទាំងនោះគឺ៖

- **រោគស្វាយកំរិតបឋម៖** ដំបៅដែលមិនមានការឈឺចាប់ (ឬដំបៅ) ដែលហៅថា "chancre" លេចឡើងនៅលើ ជុំវិញ ឬខាងក្នុងលិង្គ ទ្វារមាស មាត់ ឬទ្វារលាមក។ "chancre" លេចឡើង 10-90 ថ្ងៃបន្ទាប់ពីការប៉ះពាល់។ ដំបៅនេះពោរពេញទៅដោយបាក់តេរី និងឆ្លងខ្លាំងណាស់។ មនុស្សជាច្រើនមិនដែលសម្គាល់ឃើញchancreនោះទេ ព្រោះវាមិនមានការឈឺចាប់ ហើយអាចនៅខាងក្នុងទ្វារមាស ឬកន្លែងណាដែលមើលមិនឃើញ។ "Chancres" ជាទូទៅមានរយៈពេល 2-5 សប្តាហ៍ ហើយវានឹងអាចបាត់ទៅវិញដោយខ្លួនឯង។

- **រោគស្វាយកំរិតបន្ទាប់បន្សំ៖** ពីរបីសប្តាហ៍បន្ទាប់ពី "chancres" រលុបបាត់ កន្ទួលអាចលេចឡើងនៅលើដងខ្លួន ដៃ និង/ឬបាតជើងរបស់អ្នក។

- **រោគស្វាយកំរិតមិនទាន់ឃើញច្បាស់ដំបូង៖** ជាធម្មតាមិនមានរោគសញ្ញា និងមិនសូវងាយឆ្លងទៅដៃគូរួមភេទឡើយ។ ប្រភេទរងនៃរោគស្វាយមិនទាន់អាចឃើញច្បាស់។ នៅពេលដែលការឆ្លងដំបូងបានកើតឡើងក្នុងរយៈពេល 12 ខែមុន។

- **រោគស្វាយកំរិតមិនទាន់ឃើញច្បាស់៖** រោគសញ្ញាជាធម្មតានឹងបាត់ទៅវិញដោយខ្លួនឯង ហើយបុគ្គលនោះទំនងជាមិនសូវងាយឆ្លងទៅដៃគូរួមភេទទេ។ ទោះជាយ៉ាងណាក៏ដោយជំងឺនេះនៅតែមាននៅក្នុងខ្លួនហើយអាចបណ្តាលឱ្យមានផលវិបាកយ៉ាងធ្ងន់ធ្ងរ។

LONG BEACH HEALTH & HUMAN SERVICES

Communicable Disease Surveillance and Control Division
2525 Grand Avenue, Long Beach, CA 90815 I Phone: (562) 570-4321
Website: http://longbeach.gov/knowmore

ការយល់ដឹងអំពី
រោគស្វាយ

តើ រោគស្វាយត្រូវបានព្យាបាលយ៉ាងដូចម្តេច?

រោគស្វាយអាចព្យាបាលបានយ៉ាងងាយស្រួល និងព្យាបាលដោយថ្នាំអង់ទីប៊ីយោទិចមួយចំនួន ដែលផ្តល់ជាការចាក់ ឬថ្នាំគ្រាប់លេបតាមមាត់។ ត្រូវប្រាកដថាទាំងអ្នក និងដៃគូរួមភេទរបស់អ្នក បញ្ចប់ការព្យាបាលមុនពេលរួមភេទម្តងទៀត។ អ្នកមិនគួរព្យាយាមធ្វើរោគវិនិច្ឆ័យខ្លួនឯង ឬលេបថ្នាំដោយខ្លួនឯងឡើយ។

តើ រោគស្វាយមានផលវិបាកអ្វីខ្លះ?

ប្រសិនបើមិនបានព្យាបាលទេ រោគស្វាយអាចប៉ះពាល់ដល់បេះដូង ខួរក្បាល និងសរីរាង្គផ្សេងៗទៀត។ ការខូចខាតលេចចេញជារូបរាងនៅដំណាក់កាលចុងក្រោយនៃរោគស្វាយ ដែលគេស្គាល់ថាជារោគស្វាយកម្រិតទីបី ឬចុងគេបង្អស់។ ដំណាក់កាលនេះច្រើនតែកើតឡើងជាច្រើនទសវត្សរ៍ (10 ឆ្នាំឬច្រើនជាងនេះ) បន្ទាប់ពីការឆ្លងមេរោគ។ ផលវិបាកអាចរួមមានការខូចស្បែក ឆ្អឹង និងសរីរាង្គខាងក្នុង បញ្ហាសរសៃប្រសាទរួមទាំងការហើមនៃខួរក្បាល ពិការភ្នែក ប្រកាច់ និងឆ្កួត និងខូចខាតដល់សរសៃឈាម និងបេះដូង។ ផលវិបាកទាំងនេះអាចបណ្តាលឱ្យស្លាប់។ ទារកដែលកើតមកមានរោគស្វាយអាចបណ្តាលឱ្យកើតមិនគ្រប់ខែ ឬកើតមកមានពិការភាព។

តើ រោគស្វាយអាចការពារបានដោយរបៀបណា?

ស្រោមអនាម័យជ័រ "polyurethane" និង**ស្រោមអនាម័យខាងក្នុង** ផ្តល់ការការពារខ្លះប្រឆាំងនឹងរោគស្វាយ ប៉ុន្តែប្រហែលជាមិនអាចគ្របដណ្តប់គ្រប់កន្លែងឆ្លងទេ។ អ្នកមានផ្ទៃពោះដែលឆ្លងមេរោគគួរស្វែងរកការថែទាំមុនពេលកំណត់សម្រាល ហើយគួរត្រូវបានធ្វើតេស្តរករោគស្វាយក្នុងអំឡុងពេលត្រីមាសទីមួយ។ ប្រសិនបើរោគស្វាយត្រូវបានរកឃើញ និងព្យាបាលបានទាន់ពេល អ្នកមានផ្ទៃពោះអាចការពារពីការកើតមិនគ្រប់ខែ ឬពិការភាពពីកំណើតដល់ទារក។

ធនធាន

នាយកដ្ឋានសុខាភិបាលទីក្រុងឡុងប៊ិច

នាយកដ្ឋានសុខភាពសាធារណៈរដ្ឋកាលីហ្វ័រញ៉ា

មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺ

LONG BEACH HEALTH & HUMAN SERVICES

Communicable Disease Surveillance and Control Division
2525 Grand Avenue, Long Beach, CA 90815 I Phone: (562) 570-4321
Website: http://longbeach.gov/knowmore